**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :១៣១ អនក្រ . បក**

**អនុក្រឹត្យ**

**ស្តីពី**

**ការកំណត់កម្រៃអតិបរមា នៃកម្រៃអាជ្ញាប័ណ្ណ**

**សំរាប់អនុវត្តចំពោះអ្នកធ្វើសេវាកម្មអគ្គិសនី នៅក្នុងព្រះរាជាណាចក្រកម្ពុជា**

*******

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
- បានការឯកភាពពីគណៈរដ្ឋមន្ត្រីនាសម័យប្រជុំពេញអង្គថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ២០០១

**សម្រេច**

**មាត្រា ១.-**

អនុក្រឹត្យនេះកំណត់ អំពីកម្រិតអតិបរមានៃកម្រៃអាជ្ញាប័ណ្ណ ។ ផ្អែកតាមកម្រិតអតិបរមានេះ អាជ្ញាធរអគ្គិសនីកម្ពុជា ត្រូវគណនាកម្រៃអាជ្ញាប័ណ្ណសំរាប់ឆ្នាំការិយបរិច្ឆេទនីមួយៗ ដើម្បីធានាតុល្យភាពចំណូលចំណាយនៃកិច្ចប្រតិបត្តិការរបស់ខ្លួន ។ អ្នកសុំអាជ្ញាប័ណ្ណ និងអ្នកកាន់អាជ្ញាប័ណ្ណត្រូវបង់កម្រៃអាជ្ញាប័ណ្ណតាមការកំណត់របស់អាជ្ញាធរ ។

**មាត្រា ២.-**

រូបវន្តបុគ្គលឬនីតិបុគ្គល ដែលមានបំណងធ្វើសេវាកម្មអគ្គិសនី នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបង់

កម្រៃស្នើសុំអាជ្ញាប័ណ្ណ នៅពេលដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ ពីអាជ្ញាធរអគ្គិសនីកម្ពុជា ។ កម្រៃស្នើសុំអាជ្ញាប័ណ្ណ គឺជាចំនួនទឹកប្រាក់ដែលអ្នកស្នើសុំ ត្រូវបង់ឱ្យអាជ្ញាធរអគ្គិសនីកម្ពុជាសម្រាប់ចំណាយ ដើម្បីអនុវត្តកិច្ចការរបស់អាជ្ញាធរ ក្នុងការពិនិត្យ វិភាគ ផ្សព្វផ្សាយ ពិគ្រោះយោបល់ និងចេញអាជ្ញាប័ណ្ណ ។ កម្រិតអតិបរមានៃកម្រៃស្នើសុំអាជ្ញាប័ណ្ណត្រូវកំណត់ដូចខាងក្រោម ៖

១. ចំពោះការស្នើសុំអាជ្ញាប័ណ្ណ ធ្វើសេវាកម្មអគ្គិសនីដែលមានលក្ខណៈអនុគ្រោះ (អគ្គិសនីជនបទ) កម្រៃស្នើសុំអាជ្ញាប័ណ្ណ មិនត្រូវលើសពីហាសិបពាន់រៀល (៥០ ០០០ រៀល) ក្នុងអាជ្ញាប័ណ្ណមួយ

២. ចំពោះការស្នើសុំអាជ្ញាប័ណ្ណ ធ្វើសេវាកម្មអគ្គិសនីខ្នាតតូច តូចជាងប្រាំរយ (៥០០) គីឡូវ៉ាត់ កម្រៃស្នើសុំអាជ្ញាប័ណ្ណ មិនត្រូវលើសពីមួយរយពាន់រៀល (១០០ ០០០ រៀល) ក្នុងអាជ្ញាប័ណ្ណមួយ

៣. ចំពោះការស្នើសុំអាជ្ញាប័ណ្ណ ធ្វើសេវាកម្មអគ្គិសនីខ្នាតមធ្យម ពីប្រាំរយ (៥០០) ទៅបីពាន់ (៣០០០) គីឡូវ៉ាត់ កម្រៃស្នើសុំអាជ្ញាប័ណ្ណ មិនត្រូវលើសពីប្រាំមួយរយពាន់រៀល (៦០០ ០០០រៀល) ក្នុងអាជ្ញាប័ណ្ណមួយ

៤. ចំពោះការស្នើសុំអាជ្ញាប័ណ្ណ ធ្វើសេវាកម្មអគ្គិសនីខ្នាតធំ លើសពីបីពាន់ (៣០០០) គីឡូវ៉ាត់ កម្រៃស្នើសុំអាជ្ញាប័ណ្ណ មិនត្រូវលើសពីមួយលានរៀល (១ ០០០ ០០០ រៀល ) ក្នុងអាជ្ញាប័ណ្ណមួយ ។

កម្រៃស្នើសុំអាជ្ញាប័ណ្ណនេះ ត្រូវបង់តែម្តងគត់នៅពេលដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ ។ អាជ្ញាធរអគ្គិសនីកម្ពុជា ត្រូវបង្វិលកម្រៃនេះជូនទៅអ្នកសុំវិញ ក្នុងករណីដែលអាជ្ញាធរអគ្គិសនីកម្ពុជា សម្រេចមិនផ្តល់អាជ្ញាប័ណ្ណឱ្យអ្នកស្នើសុំ ។

រូបវន្តបុគ្គលឬនីតិបុគ្គល ដែលកំពុងធ្វើសេវាកម្មអគ្គិសនី និងមានច្បាប់អនុញ្ញាតចេញដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឬចេញដោយអាជ្ញាធរណាមួយ របស់រាជរដ្ឋាភិបាលមុនពេលអាជ្ញាធរអគ្គិសនីកម្ពុជាចាប់ផ្តើមប្រតិបត្តិការរបស់ខ្លួន អាចស្នើសុំអាជ្ញាប័ណ្ណពីអាជ្ញាធរអគ្គិសនីកម្ពុជា ដោយពុំចាំបាច់បង់កម្រៃស្នើសុំអាជ្ញាប័ណ្ណឡើយ ។

**មាត្រា ៣.–**

រូបវន្តបុគ្គលឬនីតិបុគ្គល ដែលបានទទួលអាជ្ញាប័ណ្ណពីអាជ្ញាធរអគ្គិសនីកម្ពុជា អនុញ្ញាតឱ្យធ្វើសេវាកម្មអគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបង់កម្រៃធ្វើសេវាកម្មក្រោមអាជ្ញាប័ណ្ណនេះ ជូនអាជ្ញាធរតាមការកំណត់របស់អាជ្ញាធរសម្រាប់ឆ្នាំការិយបរិច្ឆេទនីមួយៗ កម្រៃនេះហៅថាកម្រៃអាជ្ញាប័ណ្ណ ។ កម្រៃអាជ្ញាប័ណ្ណគឺជាចំនួនទឹកប្រាក់ដែលអ្នកកាន់អាជ្ញាប័ណ្ណត្រូវបង់ប្រចាំខែ ឱ្យអាជ្ញាធរចំណាយ លើកិច្ចប្រតិបត្តិការគ្រប់គ្រងសកម្មភាពសេវាកម្មអគ្គិសនីរបស់អាជ្ញាធរ ។ កម្រិតអតិបរមានៃកម្រៃអាជ្ញាប័ណ្ណ ដែលអ្នកកាន់អាជ្ញាប័ណ្ណ ត្រូវបង់តាមប្រភេទសេវាកម្មនីមួយៗ មានដូចខាងក្រោម ៖

១. ការផលិតអគ្គិសនីឬការទិញអគ្គិសនីពីក្រៅប្រទេស ៖ កម្រៃអាជ្ញាប័ណ្ណធ្វើសេវាកម្មមិនត្រូវលើសពី១,៧០ រៀលក្នុង១គីឡូវ៉ាត់ម៉ោង នៃថាមពលបញ្ចេញ ឬ ទិញចូលឡើយ

២. ការបញ្ជូនអគ្គិសនី : កម្រៃអាជ្ញាប័ណ្ណធ្វើសេវាកម្មមិនត្រូវលើសពី០,៧០ រៀលក្នុង១គីឡូវ៉ាត់ម៉ោងនៃថាមពលបញ្ជូនឡើយ

៣. ការចែកចាយនិងលក់អគ្គិសនី : កម្រៃអាជ្ញាប័ណ្ណធ្វើសេវាកម្មមិនត្រូវលើសពី១,២០ រៀលក្នុង១គីឡូវ៉ាត់ម៉ោងនៃថាមពលលក់ឡើយ

៤. ការធ្វើសេវាកម្មលក់រាយ : កម្រៃអាជ្ញាប័ណ្ណធ្វើសេវាកម្មមិនត្រូវលើសពី០,៥០ រៀលក្នុង១គីឡូវ៉ាត់ម៉ោងនៃថាមពលលក់ឡើយ

៥. ការធ្វើសេវាកម្មក្រោមអាជ្ញាប័ណ្ណផ្សេងៗទៀត ដែលមានចែងក្នុងមាត្រា ២៩ នៃច្បាប់ស្តីពីអគ្គិសនីរបស់ព្រះរាជាណាចក្រកម្ពុជា : កម្រៃអាជ្ញាប័ណ្ណធ្វើសេវាកម្មមិនត្រូវលើសពី ០,១ ភាគរយនៃថ្លៃសេវាកម្មឡើយ ។

អាជ្ញាធរអគ្គិសនីកម្ពុជា ត្រូវកំណត់ឱ្យច្បាស់លាស់ នូវកម្រៃអាជ្ញាប័ណ្ណធ្វើសេវាកម្ម សំរាប់ឆ្នាំការិយបរិច្ឆេទនីមួយៗ រួមទាំងវិធីគណនាកម្រៃអាជ្ញាប័ណ្ណធ្វើសេវាកម្មនេះ នៅក្នុងគំរោងថវិកាប្រចាំឆ្នាំ ដែលត្រូវដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសំរេច ។

**មាត្រា ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប្រធាននៃអាជ្ញាធរអគ្គិសនីកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន និងអភិបាលគ្រប់ខេត្ត-ក្រុង មានភារកិច្ចអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- ឯកសារ-កាលប្បវត្តិ